**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ......៤៩៧៧......អពដ

GENERAL DEPARTMENT OF TAXATION

L202203020490TD2230

ថ្ងៃពុធ ០៧កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារកាលបរិច្ឆេទកំណត់ដាក់ឱ្យអនុវត្តពន្ធលើចំណេញមូលធន

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន និងអ្នកជាប់ពន្ធទាំងអស់ ជ្រាបថា យោងតាមលិខិតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីសំណើសុំពន្យារពេលការអនុវត្តពន្ធលើចំណេញមូលធន និងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ រាជរដ្ឋាភិបាលបានសម្រេចឱ្យពន្យារកាលបរិច្ឆេទកំណត់ការដាក់ឱ្យអនុវត្តពន្ធលើចំណេញមូលធនរយៈពេល ០២ឆ្នាំទៀត ដោយកំណត់យក**ថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤** ជាកាលបរិច្ឆេទនៃការអនុវត្តពន្ធនេះ ក្នុងគោលដៅចូលរួមអនុវត្ត "ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣" របស់រាជរដ្ឋាភិបាល ដើម្បីជំរុញការវិនិយោគ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងអ្នកជាប់ពន្ធទាំងអស់ ជ្រាបជាព័ត៌មាន។

**អគ្គនាយកដ្ឋានពន្ធដារ**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh